គជអប
NCDD

# បទបង្ហាញ ស្តីពី
# ប្រព័ន្ធហិរញ្ញវត្ថុសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ

ដោយ សុក សុទ្ធី អនុប្រធានផ្នែកវិភាគគោលនយោបាយ និងអភិវឌ្ឍន៍. **NCDDS**

# មាតិកានៃបទបង្ហាញ

១. ការវាយតម្លៃប្រព័ន្ធហិរញ្ញវត្ថុសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ(SNA)

២. សាវតា

៣. ថវិកាសម្រាប់ SNA

៤. ផលចំណូលសម្រាប់  SNA

៥. ការផ្ទេរពីថ្នាក់ជាតិ

៦. សេចក្តីសង្ខេបអំពីថវិកា SNA

# ១. ការវាយតម្លៃប្រព័ន្ធហិរញ្ញវត្ថុសម្រាប់ SNA

## ស្ថានភាពនៅមុន ឆ្នាំ ១៩៩៣

- បានបង្កើតឡើងនៅពេលបោះពុម្ពរូបិយប័ណ្ណជាតិ
- ស្របតាមប្រព័ន្ធរដ្ឋបាល និងផែនការ
- ប្រព័ន្ធហិរញ្ញវត្ថុ/ថវិកាតាមបែបរិមជ្ឈការ
- ថវិកាខេត្ត/ក្រុង "ថវិការួមគ្នាមួយ" (រដ្ឋបាល និងមន្ទីរវិស័យនៅថ្នាក់ខេត្ត)
- ថវិកាឃុំ/សង្កាត់នៅក្នុងថវិកាស្រុក/ខណ្ឌ និងថវិកាស្រុក/ខណ្ឌ នៅក្នុងថវិកាខេត្ត/ក្រុង
- ខេត្ត/ក្រុងពិភាក្សាថវិការបស់ខ្លួនជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ការផ្ទេរមូលនិធិធ្វើឡើងតាមរយៈធនាគារជាតិ ដែលមានសាខារហូតដល់ថ្នាក់ស្រុក
- ការផ្ទេរអំណាចកាន់តែច្រើនទៅរដ្ឋបាលថ្នាក់ខេត្ត/ក្រុង

# ១. ការវាយតម្លៃប្រព័ន្ធហិរញ្ញវត្ថុសម្រាប់ SNA (ត)

**ស្ថានភាពពី ឆ្នាំ ១៩៩៣  ដល់ ១៩៩៨**

- ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ (១៩៩៣)
- ប្រព័ន្ធហិរញ្ញវត្ថុ/ថវិកាមានលក្ខណៈប្រមូលផ្តុំ
- ថវិកាខេត្ត/ក្រុង/ឃុំ-សង្កាត់ គឺជាផ្នែកមួយនៃថវិកាក្រសួងមហាផ្ទៃ
- ថវិការបស់មន្ទីរវិស័យនៅតាមខេត្ត/ក្រុងគឺជាផ្នែកមួយនៃថវិកាក្រសួងពាក់ព័ន្ធរបស់ខ្លួន
- ខេត្ត/ក្រុង/ឃុំ-សង្កាត់លំបាកអនុវត្តថវិកា (ត្រូវការលើកសំណើទៅក្រសួងមហាផ្ទៃ)
- លំបាកក្នុងការសម្របសម្រួលរវាងស្ថាប័នខ្សែទទឹង (រដ្ឋបាល និងមន្ទីរនានា)

# ១. ការវាយតម្លៃប្រព័ន្ធហិរញ្ញវត្ថុសម្រាប់ SNA (ត)

## ស្ថានភាពីឆ្នាំ ១៩៩៨ ដល់ ២០០២

- ច្បាប់ស្តីពីរបបហិរញ្ញវត្ថុខេត្ត/ក្រុងនិងការគ្រប់គ្រងទ្រព្យសម្បត្តិ(ខែកុម្ភៈ ១៩៩៨)
- ប្រព័ន្ធហិរញ្ញវត្ថុ/ថវិកាវិសហមជ្ឈការ នៅពេលដែលពុំទាន់មានច្បាប់សរីរាង្គ
- មាត្រាសំខាន់ៗខ្លះមានជាប់ទាក់ទងនឹងប្រព័ន្ធគ្រប់គ្រងរដ្ឋបាល
- ថវិកាខេត្ត/ក្រុងគ្របដណ្តប់សកម្មភាព/ការចំណាយនៅក្នុងថវិកាស្រុក/ខណ្ឌ និង ឃុំ-សង្កាត់ (សម្រាប់តែប្រាក់បៀវត្សរ៍ និងការចំណាយប្រតិបត្តិការ)
- ថវិកាខេត្តមានតិចតួចសម្រាប់គោលដៅអភិវឌ្ឍន៍
- ថវិកាចំណាយលើការអភិវឌ្ឍពឹងផ្អែកជាខ្លាំងលើថវិកាមន្ទីរវិស័យនៅថ្នាក់ខេត្ត

# ១. ការវាយតម្លៃប្រព័ន្ធហិរញ្ញវត្ថុសម្រាប់ SNA (ត)

## ស្ថានភាពពីឆ្នាំ ២០០២ មកទល់បច្ចុប្បន្ន

- ឆ្នាំ ២០០២-២០១២៖ SNAs មានថវិកាពីរបែប (ថវិកាខេត្ត/ក្រុង និង ថវិកាឃុំ/សង្កាត់)។ ថវិកាត្រូវបានធ្វើប្រតិភូកម្មសម្រាប់ថ្នាក់ក្រុង/ស្រុក/ខណ្ឌ នៅឆ្នាំ ២០១២

- ពីឆ្នាំ ២០១៣ តមក៖ SNAs មានថវិកាបីបែប (ថវិការាជធានី/ខេត្ត, ក្រុង/ស្រុក និងឃុំ)។ ថវិការាជធានី មានរួមបញ្ចូលថវិកាសម្រាប់ខណ្ឌ និងសង្កាត់ ហើយថវិកាក្រុង រួមបញ្ចូលថវិកាសម្រាប់សង្កាត់។

# ២. សាវតា

- ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (ឆ្នាំ ២០០៨)
- ច្បាប់ស្ដីពីលទ្ធកម្ម (២០១២)
- ច្បាប់ស្ដីពីរបបហិរញ្ញវត្ថុខេត្ត/ក្រុង និងការគ្រប់គ្រងទ្រព្យសម្បត្តិ (១៩៩៨)
- ច្បាប់ស្ដីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិនៃSNA (២០១១)
- អនុក្រិត្យស្ដីពីមូលនិធិឃុំ/សង្កាត់ (២០០២)
- អនុក្រិត្យស្ដីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ/សង្កាត់ (២០០២)
- អនុក្រិត្យស្ដីពីការបង្កើត និងដំណើរការមូលនិធិក្រុង/ស្រុក (២០១២)
- អនុក្រិត្យស្ដីពីការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់រដ្ឋបាលក្រុង/ស្រុក

# ៣. ថវិកាសម្រាប់ SNA

## គោលការណ៍ទូទៅ

- រង្គនៃថវិកា៖ ថ្ងៃទី ០១ ខែ មករា - ថ្ងៃទី ៣១ ខែធ្នូ

## រដ្ឋបាលថ្នាក់ក្រោមជាតិ (SNA)

- ថវិការាជធានី/ខេត្ត៖ រាជធានី ១ និងខេត្តចំនួន ២៣
- ថវិកាក្រុង/ស្រុក/ខណ្ឌ៖ ២៦ ក្រុង, ១៥៩ ស្រុក និង ៩ ខណ្ឌ
- ថវិកាឃុំ/សង្កាត់៖ ១៦៣៣ ឃុំ/សង្កាត់

# ៣. ថវិកាសម្រាប់ SNA (ត)

## ការលើកថវិការាជធានី/ខេត្ត

- គណៈអភិបាល រៀបចំថវិកាប្រចាំឆ្នាំ
- ក្រុមប្រឹក្សា៖ ការពិនិត្យកែសម្រួល ការអនុម័ត និងការតាមដានថវិកាប្រចាំឆ្នាំ
- អភិបាលខេត្តមានភារៈទទួលខុសត្រូវគាំទ្រដល់ការលើកថវិកាក្រុង/ស្រុក
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ៖ ត្រួតពិនិត្យអំពីគោលការណ៍ច្បាប់លើថវិកាសម្រាប់រាជធានី/ខេត្ត និងថវិកាក្រុង/ស្រុក (ថវិកាឆ្នាំ ២០១៣)
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធ្វើប្រតិភូកម្មអំណាចដល់អភិបាលខេត្ត និងមន្ទីរហិរញ្ញវត្ថុខេត្ត ដើម្បីពិនិត្យ និងអនុម័តលើថវិកាក្រុង/ស្រុក (ចាប់ពីឆ្នាំ ២០១៤ តទៅ)

# ៣. ថវិកាសម្រាប់ SNA (ត)

## ការអនុវត្តថវិការាជធានី/ខេត្ត

- អភិបាល៖ អនុវត្តថវិកាជូសមុខឲ្យក្រុមប្រឹក្សារបស់ខ្លួន និងរាយការណ៍អំពីថវិកាក្នុងនាមជាប្រធានរដ្ឋបាលថវិកា (ខណ្ឌ និងសង្កាត់ បានទទួលអំណាចប្រតិភូកម្មដើម្បីគ្រប់គ្រងថវិកា)
- ក្រុមប្រឹក្សា៖ តាមដានការអនុវត្តថវិកាដែលធ្វើឡើងដោយអភិបាល
- ការត្រួតពិនិត្យហិរញ្ញវត្ថុ៖ អភិបាលជាអ្នកពិនិត្យ ចាត់ចែង និងផ្តល់ទិដ្ឋាការតាមការស្នើសុំ (គម្រោងចំណាយ) និងការបញ្ជាចំណាយ
- រតនាគារខេត្ត៖ ពិនិត្យលើបញ្ជាចំណាយ និងការទូទាត់ជាក់ស្តែង
- បង្វិលអតិរេកថវិកានៅចុងឆ្នាំបញ្ចូលទៅក្នុងថវិកាជាតិវិញ។

# ៣. ថវិកាសម្រាប់ SNA (ត)

## ការលើកថវិកាក្រុង/ស្រុក

- គណៈអភិបាលលើកថវិកាប្រចាំឆ្នាំ
- ក្រុមប្រឹក្សា៖ ពិនិត្យ អនុម័ត និងតាមដានថវិកាប្រចាំឆ្នាំ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ៖ ត្រួតពិនិត្យអំពីគោលការណ៍ច្បាប់លើថវិកាសម្រាប់ក្រុង/ស្រុក (ថវិកាឆ្នាំ ២០១៣)
- អភិបាលខេត្ត និងមន្ទីរហិរញ្ញវត្ថុខេត្ត ពិនិត្យកែសម្រួល និងអនុម័តលើថវិកាក្រុង/ស្រុក (ចាប់ពីឆ្នាំ ២០១៤តទៅ)
- នៅឆ្នាំ ២០១២ ថវិកាក្រុង/ស្រុក គឺជាផ្នែកមួយនៃថវិកាខេត្ត
- ចាប់ពីឆ្នាំ ២០១៣មក ក្រុង/ស្រុកមានថវិកាដាច់ដោយឡែករបស់ខ្លួន

# ៣. ថវិកាសម្រាប់ SNA (ត)

## ការអនុវត្តថវិកាក្រុង/ស្រុក

- អភិបាល៖ អនុវត្តថវិកាជូនសមុខឲ្យក្រុមប្រឹក្សារបស់ខ្លួន និងរាយការណ៍អំពីថវិកា ក្នុងនាមជាប្រធានរដ្ឋបាលថវិកា (សង្កាត់នៅក្នុងក្រុងទទួលអំណាចប្រតិភូកម្មដើម្បីគ្រប់គ្រងថវិកា)
- ក្រុមប្រឹក្សា៖ តាមដានការអនុវត្តថវិកាដែលធ្វើឡើងដោយអភិបាល
- គ្មានមុខនាទីត្រួតពិនិត្យហិរញ្ញវត្ថុឡើយ៖ អភិបាលគឺជាពិនិត្យ ចាត់ចែង និងផ្តល់ទិដ្ឋាការតាមការស្នើសុំ (គម្រោងចំណាយ) និងការបញ្ជាចំណាយ
- រតនាគារខេត្ត៖ ពិនិត្យលើបញ្ជាចំណាយ និងការទូទាត់ជាក់ស្តែង
- បង្វិលអតិរេកថវិកានៅចុងឆ្នាំបញ្ចូលទៅក្នុងថវិកាជាតិវិញ។

# ៣. ថវិកាសម្រាប់ SNA (ត)

## ការលើកថវិកាឃុំ/សង្កាត់

- ប្រធានឃុំ/សង្កាត់៖ លើកថវិកាប្រចាំឆ្នាំ
- ក្រុមប្រឹក្សា៖ ពិនិត្យ អនុម័ត និងតាមដានថវិកាប្រចាំឆ្នាំ
- សង្កាត់ត្រូវដាក់ជូនថវិការបស់ខ្លួនដែលបានការអនុម័តគាំទ្រពីក្រុមប្រឹក្សា សម្រាប់បញ្ចូលទៅក្នុងថវិកាក្រុង ឬ រាជធានី
- អភិបាលខេត្ត៖ ពិនិត្យនិងអនុម័តលើថវិកាឃុំ ក្រោយពីមានការអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន
- ស្រុក/ក្រុង៖ គាំទ្រដល់ឃុំ/សង្កាត់ ក្នុងការលើកថវិកា
- អតិរេកថវិកានៅចុងឆ្នាំត្រូវបញ្ចូលទៅក្នុងថវិកាសម្រាប់ឆ្នាំបន្ទាប់
- ចាប់ពីឆ្នាំ ២០១៣មក ថវិកាសង្កាត់បានក្លាយជាផ្នែកមួយនៃថវិកាក្រុង និងរាជធានី

# ៣, ថវិកាសម្រាប់ SNA (ត)

## ការអនុវត្តថវិកាឃុំ/សង្កាត់

- ប្រធានឃុំ៖ អនុវត្តថវិកា និងរាយការណ៍ ក្នុងនាមជាអ្នកគ្រប់គ្រងថវិកាដែលបានទទួលអំណាចប្រតិភូកម្ម
- ក្រុមប្រឹក្សា៖ តាមដានថវិកាដែលអនុវត្តដោយប្រធានឃុំ/សង្កាត់
- រតនាគារខេត្ត (គណនេយ្យករ)៖ ពិនិត្យលើការបញ្ជាចំណាយ និងការទូទាត់ដោយប្រធានឃុំ/សង្កាត់។
- **ឃុំ៖** អតិរេកថវិកានៅចុងឆ្នាំ ត្រូវបញ្ចូលទៅក្នុងថវិកាសម្រាប់ឆ្នាំបន្ទាប់

# ៤. ផលចំណូលសម្រាប់ SNA

**យោងតាមច្បាប់ ផលចំណូលសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិគឺ៖**

- ផលចំណូលពីប្រភពក្នុងមូលដ្ឋាន៖ បានធ្វើការសិក្សា ហើយគោលនយោបាយនឹងត្រូវរៀបចំ
- ផលចំណូលពីប្រភពនៅថ្នាក់ជាតិ
- ផលចំណូលផ្សេងទៀត ដូចដែលមានចែងក្នុងច្បាប់ ឬ លិខិតបទដ្ឋានគតិយុត្តិផ្សេងទៀតដែលនៅជាធរមាន

**រាជធានី/ខេត្ត**

- ប្រភពចំណូលនៅមូលដ្ឋាន៖ ផលចំណូលពីពន្ធ និងពីប្រភពក្រៅពីពន្ធ
  - ផលចំណូលពីពន្ធ៖ មធ្យោបាយដឹកជញ្ជូន ការបំភ្លឺតាមផ្លូវថ្នល់ សត្តឃាដដ្ឋាន ដីទុកចោលទំនេរមិនប្រើប្រាស់ ប៉ាតង់ ការប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ និងទ្រព្យសម្បត្តិ
  - ផលចំណូលពីប្រភពក្រៅពីពន្ធ៖ បានមកពីការផ្គត់ផ្គង់អគ្គិសនី ការផ្គត់ផ្គង់ទឹក ការជួលទ្រព្យសម្បត្តិរដ្ឋ និងប្រភពផ្សេងទៀត
- ការផ្ទេរពីថ្នាក់ជាតិ៖ ដើម្បីបំពេញលើការខ្វះខាត

# ៤. ផលចំណូលសម្រាប់ SNA (ត)

## ក្រុង/ស្រុក

- ការផ្ទេរពីថ្នាក់ជាតិ៖ មូលនិធិក្រុង/ស្រុក

## ឃុំ/សង្កាត់

- ផលចំណូលពីប្រភពក្នុងមូលដ្ឋាន៖ ផលចំណូលពីប្រភពក្រៅពីពន្ធ ដែលបានពីការចុះបញ្ជីអត្រានុកូលដ្ឋាន កម្រៃរដ្ឋបាល និងកម្រៃពីការចេញប័ណ្ណកម្មសិទ្ធិដី
- ការផ្ទេរពីថ្នាក់ជាតិ៖ មូលនិធិឃុំ/សង្កាត់
- វិភាគទានពីដៃគូអភិវឌ្ឍន៍៖ មូលនិធិបម្រុងទុក (សម្រាប់គោលដៅជាក់លាក់)

# ៥. ការផ្ទេរពីថ្នាក់ជាតិ

## មូលនិធិឃុំ/សង្កាត់ (CSF)

- **គោលបំណងនៃមូលនិធិ៖** ដើម្បីឲ្យឃុំ/សង្កាត់អាចអនុវត្តការៈកិច្ចទូទៅរបស់ខ្លួនសម្រាប់ការចាត់ចែងរដ្ឋបាលមូលដ្ឋាន និងលើកកំពស់ការអភិវឌ្ឍនៅមូលដ្ឋាន
- **ប្រភពមូលនិធិ៖** (១) ផលចំណូលជាប្រចាំរបស់រដ្ឋាភិបាលពីប្រភពក្នុងប្រទេស និង (២) វិភាគទានពីជំនួយឥតសំណង និងកម្ចី
- **សមាសភាគនៃមូលនិធិ៖**
  - រដ្ឋបាលទូទៅមិនលើសពី ១/៣
  - ការអភិវឌ្ឍនៅមូលដ្ឋាន មិនតិចជាង ២/៣
- **រដ្ឋបាលទូទៅ**
  - ប្រាក់បំណាច់សម្រាប់សមាជិកក្រុមប្រឹក្សា និងថ្នាក់ដឹកនាំភូមិ
  - ប្រតិបត្តិការរដ្ឋបាល ទៅតាមសមាមាត្រនៃចំនួនសមាជិកក្រុមប្រឹក្សា
- **ការអភិវឌ្ឍនៅមូលដ្ឋាន៖** គណនាតាមរូបមន្ត៖
  - ចំណែកស្មើគ្នា= ៣៥%
  - ប្រជាជន = ៣៥%
  - សន្ទស្សន៍ភាពក្រីក្រ= ៣០%

# ៥. ការផ្ទេរពីថ្នាក់ជាតិ (ត)

## មូលនិធិក្រុង/ស្រុក (MDF)

- **គោលបំណងនៃមូលនិធិ៖** ផ្តល់ធនធានហិរញ្ញវត្ថុជាក់លាក់ដល់ក្រុង/ស្រុក ដោយសមធម៌ ដែលអាចព្យាករណ៍បាន និងមាននិរន្តរភាព សម្រាប់ទ្រទ្រង់ការអភិវឌ្ឍតាមមូលដ្ឋាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- **ប្រភពមូលនិធិ៖** (១) ប្រភពចំណូលជាប្រក្រតីនៅក្នុងប្រទេសរបស់រដ្ឋាភិបាល និង (២) វិភាគទានពីជំនួយឥតសំណង និងកម្ចី
- **សមាសភាគនៃមូលនិធិ៖** (១) ប្រតិបត្តិការរដ្ឋបាលទូទៅ (ប្រាក់បៀវត្សរ៍ និងថ្លៃចំណាយប្រតិបត្តិការដទៃទៀត = ២៤% នៃមូលនិធិសរុប – ប្រាក់បៀវត្សរ៍) និង (២) ការអភិវឌ្ឍនៅមូលដ្ឋាន (មូលនិធិសរុប - ប្រតិបត្តិការរដ្ឋបាលទូទៅ)

# ៥. ការផ្ទេរពីថ្នាក់ជាតិ (ត)

## មូលនិធិក្រុង/ស្រុក (MDF)

- **ប្រតិបត្តិការរដ្ឋបាលទូទៅ**

១. ប្រាក់បៀវត្សរ៍ និងបំណាច់សម្រាប់សមាជិកក្រុមប្រឹក្សា, គណៈអភិបាល និងបុគ្គលិក

២. ថ្លៃចំណាយលើប្រតិបត្តិការដទៃទៀត៖ ការគណនាតាមរូបមន្ត៖

- ចំណែកស្មើគ្នា = ៤០%
- សមាជិកក្រុមប្រឹក្សា = ២០%
- គណៈអភិបាល =២០%
- ចំនួនបុគ្គលិក =២០%

- **ការអភិវឌ្ឍនៅមូលដ្ឋាន៖** ការគណនាតាមរូបមន្ត
  - ចំណែកស្មើគ្នា = ៤០%
  - ប្រជាជន = ២០%
  - សន្ទស្សន៍ភាពក្រីក្រ = ២០%
  - ចំនួនឃុំ/សង្កាត់ = ២០%

# ៦. សេចក្តីសង្ខេបថវិកា SNA (2011-2013)

*ឯកត្តា លានដុល្លាអាមេរិក*

| SNA* | 2011 | 2012 | 2013 | *2013 (%)* |
|---|---|---|---|---|
| រាជធានី/ខេត្ត | 79,03 | 92,80 | 125,17 | *4,14%* |
| ក្រុង/ស្រុក/ខណ្ឌ (**Sida** បានរួមបញ្ចូល) | 10,37 | 14,15 | 18,43 | *0,61%* |
| ឃុំ/សង្កាត់** | 39,85 | 45,50 | 50,47 | *1,67%* |
| **សរុប** | **129,25** | **152,45** | **194,07** | ***6,42%*** |
| **ថវិកាជាតិ** | **2.462,41** | **2.692,00** | **3.023,77** | |
| **ភាគចំណែកនៃថវិកាជាតិ** | **5,25%** | **5,66%** | **6,42%** | 20,80% |

* មិនរាប់បញ្ចូលថវិកាមន្ទីរវិស័យនៅថ្នាក់ខេត្ត ឆ្នាំ 2011 = 338,95 និង 2012 = 393,43 និង 2013 = 435,17
** វិភាជន៍ពីមូលនិធិឃុំ/សង្កាត់

# ថវិកាថ្នាក់ក្រោមជាតិ

*ឯកត្តា៖ លានដុល្លាអាមេរិក*

| បរិយាយ | 2004 | 2005 | 2006 | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | % (2013) |
|---|---|---|---|---|---|---|---|---|---|---|---|
| ថវិកាជាតិសរុប | 753 | 792 | 954 | 1.156 | 1.418 | 1.815 | 2.075 | 2.462 | 2.692 | 2.139 | 100% |
| ថវិកាជាតិ | 713 | 748 | 899 | 1.091 | 1.343 | 1.697 | 1.956 | 2.333 | 2.540 | 1.938 | 91% |
| ថវិកាថ្នាក់ក្រោមជាតិ | 40 | 44 | 54 | 64 | 75 | 118 | 119 | 129 | 152 | 201 | 9% |
| ថវិការាជធានី/ខេត្ត | 25 | 28 | 35 | 42 | 52 | 89 | 82 | 89 | 107 | 130 | 65% |
| ថវិកាក្រុង/ស្រុក | | | | | | | | | | 20 | 10% |
| ថវិកាឃុំ/សង្កាត់ | 15 | 17 | 19 | 22 | 23 | 28 | 37 | 40 | 45 | 51 | 25% |

(ភាគរយនៃថវិការាជធានី ខេត្ត ក្រុង ឃុំ សង្កាត់ គឺជាភាគរយធៀបនឹងថវិកានៅថ្នាក់ក្រោមជាតិ)

# លំហូរថវិកាពីដៃគូអភិវឌ្ឍន៍ផ្សេងទៀត,

# NRML .UNICEF. UNFPA

# សូមអរគុណ!